ព្រះគ្រីស្ទដ៏មានព្រះជន្មរស់

ទីបន្ទាល់នៃពួកសាវក

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

នៅពេលយើងប្រារព្ធពិធីរំឭកចំពោះថ្ងៃប្រសូតរបស់ព្រះយេស៊ូវគ្រីស្ទ កាលពីពីរសហស្សវត្សកន្លងទៅនោះ ពួកយើងសូមថ្វាយទីបន្ទាល់របស់ពួកយើងអំពីតថភាពពិតនៃព្រះជន្មដ៏ឥតប្រៀបផ្ទឹមរបស់ទ្រង់ និងគុណធម៌ដ៏និរន្តរ៍នៃពលិកម្មធួនដ៏មហិមារបស់ទ្រង់ ។ ពុំមាននរណា ដែលមានឥទ្ធិពលដ៏ខ្លាំងមហិមាមកលើមនុស្សដែលបានរស់នៅ ហើយដែលនឹងរស់នៅលើផែនដីនេះដូចជាទ្រង់ឡើយ ។

ទ្រង់គឺជាព្រះយេហូវ៉ាដ៏មហិមានៅក្នុងគម្ពីរសញ្ញាចាស់ ហើយជាព្រះមែស៊ីនៅក្នុងគម្ពីរសញ្ញាថ្មី ។ នៅក្រោមការដឹកនាំរបស់ព្រះវរបិតាទ្រង់ នោះទ្រង់គឺជាអង្គបង្កបង្កើតនៃផែនដី ។ « គ្រប់របស់ទាំងអស់បានកើតមកដោយសារទ្រង់ ហើយក្នុងបណ្តារបស់ដែលបានកើតមកទាំងប៉ុន្មាន នោះគ្មានអ្វីណាមួយកើតមកក្រៅពីទ្រង់ឡើយ » (យ៉ូហាន ១:៣)។ ទោះជាទ្រង់គ្មានបាបក្តី ក៏ទ្រង់បានទទួលបុណ្យជ្រមុជទឹកដើម្បីបំពេញនូវគ្រប់អស់ទាំងសេចក្តីសុចរិតដែរ ។ ទ្រង់ « បានយាងចុះឡើងធ្វើការល្អ » (កិច្ចការ ១០:៣៨) ប៉ុន្តែត្រូវគេស្អប់ទៅវិញ ។ ដំណឹងល្អរបស់ទ្រង់គឺជាសារនៃសេចក្តីសុខសាន្ត និងសុជនភាព ។ ទ្រង់បានទទួចអង្វរមនុស្សគ្រប់រូបឲ្យធ្វើតាមគំរូទ្រង់ ។ ទ្រង់បានយាងតាមផ្លូវស្រុកកាលីស្ទីន ព្យាបាលអ្នកឈឺ ប្រោសអ្នកខ្វាក់ឲ្យមើលឃើញ និងប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ។ ទ្រង់បានបង្រៀនសេចក្តីពិតនៃភាពអស់កល្បជានិច្ច តថភាពពិតនៃជីវិតមុនជីវិតនៅលើផែនដីរបស់យើង គោលបំណងនៃជីវិតរបស់យើងនៅលើផែនដី និងសក្តានុពលសម្រាប់បុត្រាបុត្រីនៃព្រះនៅក្នុងបរលោកនាយ ។

ទ្រង់បានតាំងពិធីសាក្រាម៉ង់ឡើង ទុកជាការរំឭកចាំដល់ពលិកម្មធួនដ៏មហិមារបស់ទ្រង់ ។ ទ្រង់ត្រូវគេចាប់ព្រះកាយ ហើយចោទប្រកាន់ដោយមិនត្រឹមត្រូវ ត្រូវគេថ្កោលទោសដើម្បីបំពេញចិត្តមនុស្ស ហើយកាត់ទោសឲ្យសុគតនៅលើឈើឆ្កាង ត្រង់ភ្នំកាល់វ៉ារី ។ ទ្រង់បានលះបង់ព្រះជន្មរបស់ទ្រង់ ដើម្បីធ្វើឲ្យធួននឹងអំពើបាបនៃមនុស្សលោក ។ ព្រះជន្មរបស់ទ្រង់គឺជាអំណោយដ៏មហិមាជំនួសឲ្យមនុស្សទាំងអស់ដែលធ្លាប់រស់នៅលើផែនដី ។

ពួកយើង សូម ថ្លែង ទីបន្ទាល់ ជា ឧឡារិក ថា ព្រះជន្ម ទ្រង់មានសារៈសំខាន់ បំផុតនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្ស ដែលវាពុំបានចាប់ផ្តើមតែនៅក្នុងភូមិបេថ្លេហិម ហើយបញ្ចប់នៅត្រង់ភ្នំកាល់វ៉ារីនោះទេ ។ ទ្រង់គឺជាបុត្រាច្បងនៃព្រះវរបិតា ជាព្រះរាជបុត្រាបង្កើតតែមួយនៅក្នុងសាច់ឈាម ជាព្រះប្រោសលោះនៃពិភពលោក ។

ទ្រង់បានក្រោកចេញពីផ្នូរដោយមានព្រះជន្មរស់ឡើងវិញ ដើម្បីក្លាយជា « ផលដំបូងពីពួកអ្នកដែលបានដេកលក់ទៅហើយ » (កូរិនថូស ទី ១ ១៥:២០) ។ នៅពេលព្រះអម្ចាស់បានមានព្រះជន្មរស់ឡើងវិញ ទ្រង់បានយាងទៅជួបពួកអ្នកដែលទ្រង់ស្រឡាញ់ កាលពីទ្រង់ពុំទាន់សុគតនោះ ។ ទ្រង់ក៏បានផ្តល់ការងារបម្រើនៅក្នុងចំណោម « ចៀមឯទៀត » របស់ទ្រង់ (យ៉ូហាន ១០:១៦) នៅទ្វីបអាមេរិកពីជំនាន់បុរាណ ។ នៅក្នុងពិភពលោកនៃជំនាន់ថ្មី ទ្រង់ និងព្រះវរបិតាទ្រង់បានយាងមកជួបនឹងយុវជន យ៉ូសែប ស្ម៊ីធ ដើម្បីនាំមកនូវ « ការកាន់កាប់ត្រួតត្រាក្នុងកាលដែលពេលពេញកំណត់បានមកដល់ » ដូចដែលបានសន្យាទុកជាយូរមកហើយនោះ (អេភេសូរ ១:១០) ។

ព្យាការីយ៉ូសែប បានសរសេរអំពីព្រះគ្រីស្ទដ៏មានព្រះជន្មរស់ថា ៖ « ព្រះនេត្ររបស់ទ្រង់ដូចជាអណ្តាតភ្លើង ព្រះកេសារបស់ទ្រង់ស ដូចជាហិមៈសុទ្ធ ព្រះភ័ក្ត្ររបស់ទ្រង់ភ្លឺជាងពន្លឺថ្ងៃ ហើយសំឡេងរបស់ទ្រង់ដូចជាសូរនៃទឹកច្រើន គឺសំឡេងនៃព្រះយេហូវ៉ា ដោយមានព្រះបន្ទូលថា ៖

« យើងជាដើម ហើយជាចុង យើងជាព្រះអង្គដែលមានព្រះជន្មរស់នៅ យើងជាអង្គដែលត្រូវគេធ្វើគត យើងជាព្រះគាំទ្ររបស់អ្នកជាមួយព្រះវរបិតា » (គ. និង ស. ១១០:៣–៤) ។

ព្យាការីរូបនេះក៏បានប្រកាសអំពីទ្រង់ផងដែរថា ៖ « ហើយឥឡូវនេះ បន្ទាប់ពីទីបន្ទាល់ជាច្រើនដែលបានថ្លែងអំពីទ្រង់ នេះគឺជាទីបន្ទាល់ចុងក្រោយបង្អស់ ដែលយើងខ្ញុំសូមថ្លែងអំពីទ្រង់ ៖ គឺថាទ្រង់មានព្រះជន្មរស់នៅ !

« ដ្បិតយើងខ្ញុំបានឃើញទ្រង់គង់នៅខាងស្តាំព្រះហស្តនៃព្រះ ហើយយើងខ្ញុំបានឮសំឡេង ដែលថ្លែងទីបន្ទាល់ថា ទ្រង់គឺជាបុត្រាបង្កើតតែមួយនៃព្រះវរបិតា—

« ថាដោយសារព្រះអង្គ និងតាមរយៈព្រះអង្គ ហើយពីព្រះអង្គ នោះពិភពលោកទាំងឡាយមានឡើង ហើយបានបង្កើតមក ហើយបណ្តាជននៅទីនោះ គឺជាបុត្រាបុត្រីបង្កើតចំពោះព្រះ » (គ. និង ស. ៧៦:២២–២៤) ។

ពួកយើង សូម ប្រកាសជាឧឡារិក ថា បព្វជិតភាព របស់ទ្រង់ និង សាសនាចក្ររបស់ទ្រង់ ត្រូវបានស្តារឡើងវិញនៅលើផែនដី— « ដែលបានស្អាងឡើងលើជើងជញ្ជាំងនៃ ... ពួកសាវក និងពួកព្យាការី ហើយព្រះយេស៊ូវគ្រីស្ទនោះឯង ទ្រង់ជាថ្មជ្រុងយ៉ាងឯក » (អេភេសូរ ២:២០) ។

ពួកយើងសូមធ្វើទីបន្ទាល់ថា ទ្រង់នឹងយាងមកផែនដីវិញនៅថ្ងៃណាមួយ ។ « នោះសិរីល្អនៃព្រះយេហូវ៉ានឹងសម្តែងមក គ្រប់មនុស្សទាំងឡាយនឹងបានឃើញព្រមគ្នា » (អេសាយ ៤០:៥) ។ ទ្រង់នឹងគ្រប់គ្រងជាស្តេចលើអស់ទាំងស្តេច ហើយសោយរាជ្យជាព្រះអម្ចាស់លើអស់ទាំងព្រះអម្ចាស់ ហើយគ្រប់ទាំងជង្គង់ត្រូវលុតចុះ ហើយគ្រប់ទាំងអណ្តាតនឹងថ្លែងថ្វាយបង្គំទ្រង់ ។ យើងម្នាក់ៗនឹងត្រូវឈរទទួលការជំនុំជម្រះពីទ្រង់ ស្របតាមកិច្ចការ និងសេចក្តីប៉ងប្រាថ្នាទាំងឡាយនៃដួងចិត្តរបស់យើង ។

ក្នុងនាមជាពួកសាវករបស់ទ្រង់ដែលបានតែងតាំងឡើងដោយត្រឹមត្រូវ ពួកយើងសូម ថ្លែង ទីបន្ទាល់ ថា— ព្រះយេស៊ូវគឺជា ព្រះ គ្រីស្ទ ដ៏ មាន ព្រះជន្ម រស់ និង ជាព្រះរាជបុត្រាអមតភាពរបស់ព្រះ ។ ទ្រង់គឺជាព្រះរាជាអេម៉ាញូអែលដ៏មហិមា ដែលសព្វថ្ងៃនេះគង់នៅខាងស្តាំព្រះហស្តនៃព្រះវរបិតារបស់ទ្រង់ ។ ទ្រង់គឺជាពន្លឺ ជាជីវិត ហើយជាសេចក្តីសង្ឃឹមនៃពិភពលោក ។ មាគ៌ារបស់ទ្រង់គឺជាមាគ៌ាដែលនាំទៅរកសុភមង្គលនៅក្នុងជីវិតនេះ និងជីវិតដ៏នៅអស់កល្បជានិច្ចក្នុងបរលោកនាយ ។ សូមថ្វាយអំណរព្រះគុណចំពោះព្រះសម្រាប់ព្រះរាជបុត្រាដ៏ទេវភាពរបស់ទ្រង់ ដែលជាអំណោយដ៏ឥតប្រៀបផ្ទឹមបាន ។ ☙

គណៈប្រធានទីមួយ

Gordon B. Hinckley
Thomas S. Monson
James E. Faust

កូរ៉ុមនៃពួកដប់ពីរនាក់

Boyd K. Packer
L. Tom Perry
David B. Haight
Neal A. Maxwell
Russell M. Nelson
Dallin H. Oaks
M. Russell Ballard
Joseph B. Wirthlin
Richard G. Scott
Robert D. Hales
Jeffrey R. Holland
Henry B. Eyring

ថ្ងៃទី ១ ខែមករា ឆ្នាំ ២០០០

Unofficial poster layout of the text published on churchofjesuschrist.org. Not an official publication of The Church of Jesus Christ of Latter-day Saints. Generated by Urim, urim.samuelbaird.com